# ពេទ្យសត្វជំនាញបង្កាត់ពូជសត្វតាមបែបសិប្បនិម្មិត

## ខេត្តកំពង់ឆ្នាំង

គម្រោងឧបត្ថម្ភថវិកា
ដោយសហភាពអឺរ៉ុប



លោក ហេង មករា មន្ត្រីបសុពេទ្យប្រចាំការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្តកំពង់ឆ្នាំង កំពុងពិនិត្យមើលស្ពែមមុនពេលយកទៅប្រើដើម្បីផ្តល់សេវាបង្កាត់សិប្បនិម្មិតដល់កសិករចិញ្ចឹមជ្រូក។

> *ខ្ញុំចង់ឲ្យប្រជាជនរីកចម្រើនដោយសារការចិញ្ចឹមសត្វ ។ ចង់ឲ្យការចិញ្ចឹមសត្វហ្នឹងរីកចម្រើនរហូតដល់ដូចបណ្តាប្រទេសផ្សេងៗ ដែលនាំចូលបច្ចេកវិទ្យាមកឲ្យយើង ។ គេដល់កំពូលអ៊ីចឹង យើងចង់ឲ្យដូចគ្នាដែរ* — ហេង មករា

ចំពោះបសុពេទ្យ ហេង មករា ការប្រើប្រាស់សេវាបង្កាត់ពូជសិប្បនិម្មិតបាននាំមកនូវផលប្រយោជន៍ជាច្រើនសម្រាប់កសិករខ្មែរ។

លោក មករា បម្រើការងារនៅការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្តកំពង់ឆ្នាំង ឯកទេសផ្នែកបង្កាត់ពូជជ្រូកតាមបែបសិប្បនិម្មិត។

លោកបានសម្គាល់ឃើញថា ចំនួនសត្វជ្រូកដែលកើតមកតាមរយៈការបង្កាត់សិប្បនិម្មិតមានការកើនឡើង ដោយសារតែអត្រាបង្កកំណើតប្រសើរជាងមុន ហើយជ្រូកក៏លូតលាស់ធំធាត់លឿនជាងមុនដែរ។

លោកពន្យល់ថា៖ "យើងបានធ្វើបទបង្ហាញញឹកញាប់ដល់កសិករចិញ្ចឹមជ្រូក ហើយយើងបានខិតខំប្រឹងប្រែងដើម្បីផ្សព្វផ្សាយអំពីបច្ចេកទេសចិញ្ចឹមបែបទំនើបនេះដល់កសិករនៅតាមភូមិនានា"។

កម្មវិធីបង្កាត់ពូជសិប្បនិម្មិត គឺជាផ្នែកមួយនៃគម្រោងដែលគាំទ្រដោយសហភាពអឺរ៉ុបសម្រាប់វិស័យកសិកម្មនៅកម្ពុជា។ ក្រៅពីការងារផ្នែកសត្វជ្រូក លោក មករា ក៏បានបង្ហាញផងដែរពីរបៀបដាំដុះពូជស្មៅដែលផ្តល់ទិន្នផលខ្ពស់ និងរបៀបចិញ្ចឹមមាន់ឲ្យមានប្រសិទ្ធភាព។ ការងារទាំងអស់នេះបានក្លាយជាការងារប្រចាំថ្ងៃរបស់លោកក្នុងនាមជាមន្ត្រីបសុពេទ្យរបស់រដ្ឋ។

លោក មករា បានពន្យល់ទាក់ទងនឹងការបង្ហាត់បង្ហាញដល់កសិករឲ្យចេះអនុវត្តការបង្កាត់ដោយខ្លួនឯងសម្រាប់សត្វរបស់ខ្លួន ដើម្បីឲ្យពួកគាត់មានការយល់ដឹងកាន់តែច្បាស់។ "ជាទូទៅ ទាក់ទងនឹងអ្នកដែលមកយក ស្ពែម ឬសេវាពីខាងយើង យើងបង្រៀនគាត់ឲ្យចេះដាក់ អោយចេះកំណត់ថាតើជ្រូករកឈ្មោលយ៉ាងម៉េច គឺយើងបង្រៀនគាត់ឲ្យចេះពីបញ្ហាហ្នឹង"។

"បើសិនជាយើងទៅបង្កាត់កន្លែងគាត់ អត់ដូចគាត់នៅផ្ទាល់ខ្លួនឯងទេ ព្រោះមានតែគាត់ទេទើបដឹងថា ជ្រូកគាត់រកឈ្មោលប៉ុន្មានថ្ងៃមកហើយ ល្មម ឬមិនល្មម ។ យើងមិនដឹងទេ ព្រោះយើងមិននៅជិតនឹងជ្រូកដូចគាត់" ។

ដើម្បីឲ្យកសិករទូទាំងប្រទេសកម្ពុជាបានទទួលផលប្រយោជន៍ពិតៗ លោក មករា បានទទូចថា ពួកគាត់គួរតាំងចិត្តចិញ្ចឹមសត្វពេញមួយឆ្នាំ ពោលមិនមែនតែនៅពេលដែលតម្លៃទីផ្សារកើនឡើង ដូចជាក្នុងអំឡុងពេលបុណ្យទាននោះឡើយ បើទោះបីជាសព្វថ្ងៃ

មនុស្សជាច្រើនកំពុងតែធ្វើបែបនេះក្តី។

"ការចិញ្ចឹមជ្រូកដោយការបង្កាត់សិប្បនិម្មិត គឺល្អបំផុត។ វាមានប្រយោជន៍ច្រើន គឺមិនឆ្លងរោគមិនខូចជ្រូក កូនកើតមកល្អ ដោយសារយើងមានពូជល្អ"។

"តាំងពីមានការបង្កាត់សិប្បនិម្មិតមក ធ្វើឲ្យគាត់អត់ចាយទុនច្រើនលើការដាក់បា អត់សូវចំណាយពេលវេលាច្រើន"។

កាលពីមុន ជ្រូកបាត្រូវបានប្រើដើម្បីបង្កាត់ពូជជាមួយនឹងជ្រូកមេ ហើយជ្រូកបាដែលល្អ ក៏ទាមទារតម្លៃសេវាខ្ពស់ខ្លាំងដែរ។ ទន្ទឹមនឹងនេះ ក៏មិនធានាថាការបង្កាត់នោះជោគជ័យឡើយ ដែលមានន័យថា ពេលខ្លះ កសិករត្រូវដាក់បាច្រើនដង ។ នៅពេលនេះ កសិករអាចចៀសវាងការចំណាយបែបនោះបាន។

ការបង្កាត់ពូជសិប្បនិម្មិតនេះ ហាក់មានការពេញនិយមជាច្រើន ហើយលោក មករា បានធ្វើការជាមួយកសិករ ជាង១០០គ្រួសារ នៅក្នុងខេត្តកំពង់ឆ្នាំង ដែលក្នុងនោះ កសិករប្រមាណ៧០គ្រួសារ បានសម្រេចចិត្តជ្រើសរើសយកវិធីសាស្ត្រនេះ ហើយពួកគេទាំងអស់គ្នា មានការពេញចិត្តយ៉ាងខ្លាំង។

"ខ្ញុំចង់ឲ្យប្រជាជនរីកចម្រើនដោយសារការចិញ្ចឹមសត្វ ។ ចង់ឲ្យការចិញ្ចឹមសត្វហ្នឹងរីកចម្រើនរហូតដល់ដូចបណ្តាប្រទេសផ្សេងៗ ដែលនាំចូលបច្ចេកវិទ្យាមកឲ្យយើង ។ គេដល់កំពូល យើងចង់ឲ្យដូចគ្នាដែរ"។



លោក ហេង មករា មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តកំពង់ឆ្នាំង ។